

# វិជ្ជបណ្ឌិត

Alyson Curro

Let's Read

The Asia Foundation




កាលពីព្រេងនាយ មានកុមារីម្នាក់ឈ្មោះ ឃឹនវឹនយូ។ នាងជាក្មេងស្រីដែលចូលចិត្តមុខវិជ្ជាគណិតវិទ្យាណាស់។ កាលពីនៅតូច នាងចង់ក្លាយជាគ្រូបង្រៀនម្នាក់។ នៅពេលនោះ នាងតែងតែលេង ដើរតួជាគ្រូនិងសិស្សជាមួយបងប្អូនប្រុសស្រីរបស់នាង។



ក្រោយមក ឃីនវីនយូបានប្រឡងជាប់បាក់ឌុបដោយទទួលបានពិន្ទុយ៉ាងល្អ។ នៅពេលនោះ ឃីនវីនយូក៏បានប្ដូរចិត្តចង់ក្លាយទៅជាវេជ្ជបណ្ឌិតវិញ។ ឪពុករបស់នាងនៅតែគាំទ្រការសម្រេចចិត្តរបស់នាងដែលចង់ក្លាយជាវេជ្ជបណ្ឌិត ព្រោះគ្មាននរណាម្នាក់នៅក្នុងគ្រួសាររបស់គាត់ជាវេជ្ជបណ្ឌិតឡើយ។ ជាមួយគ្នានេះ ឪពុករបស់នាងជឿជាក់លើ ឃីនវីនយូ ដែលមានភាពវៃឆ្លាត និងក្ដីអាណិតអាសូរ ដើម្បីក្លាយជាវេជ្ជបណ្ឌិតដ៏ល្អម្នាក់។



ឪពុករបស់នាងពិតជាគិតបានត្រឹមត្រូវមែន។ ឃីនវីនយូ បាន ក្លាយទៅជាវេជ្ជបណ្ឌិតដ៏ពូកែម្នាក់ក្នុងការព្យាបាលផ្នែកជំងឺ ស្ត្រី ជាពិសេសស្ត្រីមានផ្ទៃពោះ។ នាងគឺជាវេជ្ជបណ្ឌិតដែល ធ្វើការឱ្យរដ្ឋាភិបាល អស់រយៈពេល២២ឆ្នាំ។ វេជ្ជបណ្ឌិត ឃីនវី នយូ មិនត្រឹមតែពូកែ និងឆ្លាតប៉ុណ្ណោះទេ នាងថែមទាំងបាន យកចិត្តទុកដាក់ចំពោះមនុស្សទូទៅផងដែរ។ បន្ទាប់ពីបាតុកម្ម នៅឆ្នាំ១៩៨៨ នៅក្នុងប្រទេសភូមា វេជ្ជបណ្ឌិត ឃីនវីនយូ បាន សង្កេតឃើញថាមានប្រជាជនក្រីក្រជាច្រើននៅទីក្រុងរ៉ង់ហ្គូន។ នាងគិតថាការជួយប្រជាជនភូមា រួមទាំងជនក្រីក្រផងដែរ គឺជា កាតព្វកិច្ចរបស់នាង។



នៅឆ្នាំ១៩៩៦ វេជ្ជបណ្ឌិត ឃឹនវីនយូ បានប្តូរទៅធ្វើការជាអ្នកស្ម័គ្រចិត្តនៅមន្ទីរពេទ្យឥស្លាមដោយឥតគិតថ្លៃមួយនៅកណ្តាលទីក្រុងរ៉ង់ហ្គូន។ មន្ទីរពេទ្យនោះបានផ្តល់នូវការព្យាបាលដោយឥតគិតថ្លៃដល់ប្រជាជនក្រីក្រដោយមិនប្រកាន់ជាតិសាសន៍ និងសាសនា។ មុនដំបូង វេជ្ជបណ្ឌិត និងក្រុមគ្រូពេទ្យទាំងអស់សុទ្ធតែជាអ្នកកាន់សាសនាឥស្លាម។ ប៉ុន្តែសព្វថ្ងៃនេះវេជ្ជបណ្ឌិត និងក្រុមគ្រូពេទ្យទាំងអស់ មានកាន់សាសនាផ្សេងៗគ្នា ដូចជាសាសនាឥស្លាម សាសនាព្រះពុទ្ធ និងសាសនាគ្រឹស្ត ដូចជាអ្នកជំងឺដែរ។ សហគមន៍ អ្នកកាន់សាសនាឥស្លាមរបស់ប្រទេសភូមា តែងតែបរិច្ចាគប្រាក់យ៉ាងទៀងទាត់ទៅមន្ទីរពេទ្យដើម្បីឱ្យមន្ទីរពេទ្យអាចដំណើរការទៅបាន។



២០ឆ្នាំក្រោយមក វេជ្ជបណ្ឌិត ឃីនវីនយូ នៅតែបន្តធ្វើការស្ម័គ្រចិត្តនៅមន្ទីរពេទ្យឥស្លាមនោះដដែល។ គាត់តែងតែរវល់នឹងកិច្ចការងារជានិច្ច ព្រោះមានអ្នកជំងឺជាច្រើនឈរតម្រង់ជួរដើម្បីទទួលការព្យាបាលពីគាត់។ ជារៀងរាល់ខែ មន្ទីរពេទ្យនេះបានជួយស្ត្រីមានផ្ទៃពោះជាច្រើនសម្រាលកូន។ ក្រោយពេលសម្រាល វេជ្ជបណ្ឌិត ឃីនវីនយូ តែងតែបន់ស្រន់សុំឱ្យទារកទាំងនោះចេះស្រឡាញ់គ្នាទៅវិញទៅមកនៅក្នុងពិភពលោកនេះ។



សូមសរសេរអំពីរឿងរ៉ាវរបស់អ្នក នៅលើក្រដាសមួយសន្លឹក
ដោយការឆ្លើយនឹងសំណួរដូចខាងក្រោម។
តើនៅពេលណាដែលអ្នកសប្បាយចិត្តបំផុត?
តើអ្នកចូលចិត្តធ្វើអ្វីខ្លះ?
ចូរពិពណ៌នាអំពីពេលដែលលំបាកបំផុតដែលអ្នកបាន
ជួបប្រទះ។
ចូរប្រាប់ពីរឿងរ៉ាវក្នុងពេលអនាគតរបស់អ្នក។
តើអ្នកមានក្តីស្រមៃចង់ធ្វើអ្វី?



ចូរគូររូបរបស់អ្នក។

# Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*The Doctor*, Author: Alyson Curro. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC-BY-4.0.

This work is a modified version of the original story. © The Asia Foundation, 2021. Some rights reserved. Released under CC-BY-4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/

Contributing translators: